**ខ និងលក្ខខណ្ឌគ្រប់គ្រង**
**"ការប្រកួតលើប្រសិទ្ធភាពប្រើប្រាស់អគ្គិសនី"**

ការប្រកួតលើប្រសិទ្ធភាពប្រើប្រាស់ថាមពលអគ្គិសនី "ការប្រកួត" គឺជាយុទ្ធនាការធ្វើឡើងដោយធនាគារកម្ពុជាសាធារណៈ ភីអិលស៊ី (លេខចុះបញ្ជីពាណិជ្ជកម្ម ០០០០៣៩៣៦) ("ធនាគារកម្ពុ")។ ខ និងលក្ខខណ្ឌគ្រប់គ្រងការប្រកួតនេះមានដូចខាងក្រោម៖

## ១. រយៈពេលប្រកួត

១.១ ការប្រកួតនេះនឹងចាប់ផ្តើមចាប់ពីថ្ងៃទី១ ខែសីហា ឆ្នាំ២០២៥ រហូតដល់ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២៥ រាប់បញ្ចូលទាំងកាលបរិច្ឆេទចាប់ផ្តើម និងបញ្ចប់ ឬកាលបរិច្ឆេទផ្សេងទៀត ដែលបានកំណត់ដោយធនាគារកម្ពុ ("រយៈពេលយុទ្ធនាការ")។

## ២. សិទ្ធិចូលរួម

២.១ ការប្រកួតនេះបើកចំហរដូចខាងក្រោម៖

ក. អតិថិជនថ្មីរបស់ធនាគារដែលបើកគណនីប្រាក់បញ្ញើនៅធនាគារកម្ពុ ហើយចុះឈ្មោះប្រើប្រាស់សេវាទូទាត់វិក្កយអគ្គិសនីកម្ពុជាស្វ័យប្រវត្តិ ក្នុងអំឡុងពេលយុទ្ធនាការ។

ខ. អតិថិជនចាស់របស់ធនាគារកម្ពុដែលបានចុះឈ្មោះ ឬប្រើប្រាស់សេវាទូទាត់វិក្កយបត្រអគ្គិសនីកម្ពុជាស្វ័យប្រវត្តិក្នុងអំឡុងពេលយុទ្ធនាការ។

២.២ បុគ្គលដូចខាងក្រោមមិនមានសិទ្ធិចូលរួមយុទ្ធនាការនេះទេ៖

ក. អតិថិជនមិនមែនរូបវន្តបុគ្គល មានដូចជាក្រុមហ៊ុនឯកកម្មសិទ្ធិ ក្រុមហ៊ុនសហកម្មសិទ្ធិ នីតិបុគ្គល សមាគម ក្លិប សាលារៀន និងសង្គម

ខ. បុគ្គលដែលមានសតិមិនគ្រប់គ្រាន់

គ. បុគ្គលដែលតុលាការប្រកាសសាលក្រមក្ស័យធន ឬបណ្តឹងតាមផ្លូវច្បាប់ក្នុងទម្រង់ណាមួយលើរូបគាត់

ឃ. បុគ្គលដែលមានគណនីនៅធនាគារមានកំណត់ត្រាទូទាត់យឺត ឬមិនល្អ ដូចបានកំណត់ដោយធនាគារ និង

ង. បុគ្គលិកសម្ព័ន្ធធនាគារកម្ពុ។

## ៣. យន្តការប្រកួត

៣.១ សេវាកម្មក្នុងការប្រកួតនេះ គឺសេវាទូទាត់វិក្កយបត្រអគ្គិសនីកម្ពុជាដែលធ្វើឡើងតាមរយៈការប្រើប្រាស់សេវាទូទាត់ស្វ័យប្រវត្តិតាមរយៈធនាគារកម្ពុ។

៣.២ ដើម្បីមានគុណវុឌ្ឍិសម្រាប់យុទ្ធនាការនេះ៖

ក. អតិថិជនត្រូវចុះ**ឈ្មោះប្រើប្រាស់ដោយជោគជ័យ សម្រាប់សេវាទូទាត់វិក្កយបត្រអគ្គិសនីកម្ពុជាស្វ័យប្រវត្តិ** តាមរយៈធនាគារកម្ពុ។

ខ. អតិថិជនត្រូវធ្វើការទូទាត់វិក្កយបត្រដោយជោគជ័យ**ក្នុងរយៈពេលបួន (៤) ខែជាប់ៗគ្នា** ក្នុងអំឡុងយុទ្ធនាការ ដូចខាងក្រោម៖

| ការទូទាត់ស្វ័យប្រវត្តិរបស់អតិថិជនក្នុងខែ ឆ្នាំ២០២៥ | យុទ្ធនាការ |
|---|---|
| ខែសីហា ឬមុនខែសីហា | ខែសីហា - ខែវិច្ឆិកា |
| ខែកញ្ញា | ខែកញ្ញា - ខែធ្នូ |
| ខែតុលា | ខែតុលា - ខែមករា |
| ខែវិច្ឆិកា | ខែវិច្ឆិកា - ខែកុម្ភៈ |

គ. ការទូទាត់ត្រូវដំណើការ**ដោយមិនមានការខកខាន ឬយឺតយ៉ាវ** ដោយសារមិនមានប្រាក់គ្រប់គ្រាន់ ឬហេតុផលណាមួយផ្សេងទៀត។

## ៤. ការជ្រើសរើសអ្នកឈ្នះ និងរង្វាន់

៤.១ អ្នកឈ្នះរង្វាន់ប្រចាំខែ

ក. ការគណនាភាគរយជាមធ្យម (%) លើការកាត់បន្ថយការប្រើប្រាស់ក្នុងវិក្កយបត្រអគ្គិសនីប្រចាំខែ ក្នុងរយៈពេល ៤ ខែ ធៀបនឹងខែជាមូលដ្ឋានរបស់អតិថិជន (ឧ.វិក្កយបត្រខែសីហា ធៀបនឹងខែកញ្ញា - ខែវិច្ឆិកា ឆ្នាំ២០២៥) ត្រូវបានធ្វើឡើងដោយស្វ័យប្រវត្តិដោយប្រព័ន្ធ។

ខ. អតិថិជនចំនួនប្រាំ (៥) រូបដែលមានភាគរយខ្ពស់លើការកាត់បន្ថយការប្រើប្រាស់ក្នុងខែនីមួយៗនឹងត្រូវបានជ្រើសរើសជាអ្នកឈ្នះ។

គ. អ្នកឈ្នះចំនួនប្រាំ (៥) រូបទទួលបានប័ណ្ណជាសាច់ប្រាក់ចំនួន **២០ ដុល្លារអាមេរិក**។

៤.២ អ្នកឈ្នះរង្វាន់ធំ

ក. មានតែអតិថិជនម្នាក់ប៉ុណ្ណោះ ដែលមានភាគរយខ្ពស់បំផុតលើការកាត់បន្ថយការប្រើប្រាស់ទូទៅក្នុងអំឡុងយុទ្ធនាការនឹងត្រូវបានជ្រើសរើសជាអ្នកឈ្នះរង្វាន់ធំ។

ខ. អ្នកឈ្នះរង្វាន់ធំនឹងទទួលបានវ៉ាលីមួយដ៏គួរឱ្យទាក់ទាញម៉ាក American Flyer Luggage។

៤.៣ ឧទាហរណ៍នៃការជ្រើសរើសអ្នកឈ្នះមានដូចខាងក្រោម៖

អតិថិជនទាំងពីរ ក និង ខ បានចូលរួមក្នុងអំឡុងខែសីហា។

អតិថិជន ក

| ខែ | ទឹកប្រាក់ក្នុងវិក្កយបត្រ (ដុល្លារអាមេរិក) | កើន/(ថយ) សុទ្ធ (ដុល្លារអាមេរិក) |
|---|---|---|
| ខែសីហា | ១០០ | - |
| ខែកញ្ញា | ១០៥ | ៥ |
| ខែតុលា | ៩៥ | (១០) |
| ខែវិច្ឆិកា | ៧០ | (២៥) |
| មធ្យម | (១០៥ + ៩៥ + ៧០)/៣ = ៩០ | ៥+(-១០)+(-២៥)/៣=(១០) |
| % នៃការកាត់បន្ថយការប្រើប្រាស់ | | =១០/៩០<br>= ១១,១១% |

អតិថិជន ខ

| ខែ | ទឹកប្រាក់ក្នុងវិក្កយបត្រ (ដុល្លារអាមេរិក) | កើន/(ថយ) សុទ្ធ (ដុល្លារអាមេរិក) |
|---|---|---|
| ខែសីហា | ៥០ | - |
| ខែកញ្ញា | ៤៥ | (៥) |
| ខែតុលា | ៤០ | (៥) |
| ខែវិច្ឆិកា | ៣៥ | (៥) |
| មធ្យម | (៤៥ + ៤០ + ៣៥)/៣ = ៤០ | ៥+(៥)+(៥)/៣=(៥) |
| % នៃការកាត់បន្ថយការប្រើប្រាស់ | | =៥/៤០<br>= ១២,៥០% |

**អតិថិជន ខ នឹងត្រូវបានជ្រើសរើសជាអ្នកឈ្នះ ដោយសារ % ឬការកាត់បន្ថយការប្រើប្រាស់មានកម្រិតខ្ពស់បំផុត។**

- ក្នុងករណីមានអតិថិជនលើសពីម្នាក់ដែលមានភាគរយ (%) ដូចគ្នា លើការបន្ថយការប្រើប្រាស់ ការជ្រើសរើសនឹងផ្អែកលើអតិថិជន ដែលមានសមតុល្យជាមធ្យមប្រចាំថ្ងៃខ្ពស់បំផុតក្នុងគណនីរបស់ របស់ពួកគេនៅធនាគារកម្ពុ ក្នុងអំឡុងពេលយុទ្ធនាការ។

  សមតុល្យជាមធ្យមប្រចាំថ្ងៃសំដៅលើសមតុល្យគណនីបញ្ចប់ចុងថ្ងៃ ដែលបានបែងចែកតាមចំនួនថ្ងៃសរុប ក្នុងអំឡុងពេលយុទ្ធនាការ។

៤.៤ ស្ថានភាពទូទាត់វិក្កយបត្រអគ្គិសនីកម្ពុជាស្វ័យប្រវត្តិរបស់អ្នកឈ្នះនៅធនាគារកម្ពុត្រូវរក្សា "សកម្មភាព" បន្ទាប់ពីបានទទួលរង្វាន់។

៤.៥ អ្នកឈ្នះនឹងត្រូវប្រកាសលើបណ្តាញផ្សព្វផ្សាយផ្លូវការរបស់ធនាគារ (ដូចជាគេហទំព័រ និងបណ្តាញសង្គម)។

៤.៦ ធនាគារនឹងទំនាក់ទំនងទៅអ្នកឈ្នះតាមរយៈព័ត៌មានទំនាក់ទំនងលម្អិត ដែលមាននៅក្នុងកំណត់ត្រារបស់ធនាគារ។ អតិថិជនត្រូវទទួលខុសត្រូវ ដើម្បីធានាថា ព័ត៌មានទំនាក់ទំនងរបស់ខ្លួនត្រូវបានធ្វើបច្ចុប្បន្នភាព។

## ៥. ខ និងលក្ខខណ្ឌទូទៅ

៥.១ តាមរយៈការចូលរួមប្រកួតនេះ អ្នកមានសិទ្ធិចូលរួមយល់ព្រមអនុវត្តតាមខ និងលក្ខខណ្ឌអំពីសេវាទូទាត់វិក្កយបត្រអគ្គិសនីកម្ពុជាស្វ័យប្រវត្តិ (រាប់បញ្ចូលទាំងការធ្វើវិសោធនកម្ម ការកែតម្រូវ និង/ឬការកែប្រែទៅលើខ និងលក្ខខណ្ឌនេះ)។

៥.២ អ្នកមានសិទ្ធិចូលរួមទទួលស្គាល់ និងព្រមព្រៀងថា កំណត់ត្រានៃប្រតិបត្តិការដែលមាននៅធនាគារកម្ពុ និងសេចក្តីសម្រេចរបស់ធនាគារកម្ពុពាក់ព័ន្ធនឹងបញ្ហាណាមួយលើយុទ្ធនាការនេះត្រូវចាត់ទុកជាស្ថាពរ ដាច់ស្រេច និងភ្ជាប់កាតព្វកិច្ចអនុវត្តចំពោះពួកគេ។ ធនាគារនឹងមិនទទួលយកការស្នើសុំ ឬការឆ្លើយតាមណាមួយពីអ្នកមានសិទ្ធិចូលរួម និង/ឬភាគីទីបីលើបញ្ហាដែលពាក់ព័ន្ធនឹងការប្រកួតនេះ។

៥.៣ អ្នកមានសិទ្ធិចូលរួមបានព្រមព្រៀង និងយល់ព្រមឱ្យធនាគារកម្ពុដំណើរការ ប្រមូល ប្រើប្រាស់ និងរក្សាទុករាល់ព័ត៌មានរបស់អ្នកមានសិទ្ធិចូលរួម ដែលពាក់ព័ន្ធនឹងការទូទាត់វិក្កយបត្រអគ្គិសនីកម្ពុជាសម្រាប់គោលបំណងនៃយុទ្ធនាការនេះ។

៥.៤ ធនាគារកម្ពុមិនទទួលខុសត្រូវ ឬទទួលយកការទទួលខុសត្រូវក្នុងទម្រង់ណាមួយ និងការទទួលខុសត្រូវដែលផ្តើមចេញពី ឬទទួលរងដោយសារអ្នកមានសិទ្ធិចូលរួម និង/ឬភាគីទីបី ដែលកើតឡើងដោយផ្ទាល់ ឬប្រយោលដោយសារយុទ្ធនាការនេះ លុះត្រាតែវាជាការធ្វេសប្រហែសទាំងស្រុង ឬការប្រព្រឹត្តកំហុសដោយចេតនារបស់ធនាគារពាក់ព័ន្ធនឹងយុទ្ធនាការនេះ។

៥.៥ ធនាគារកម្ពុនឹងមិនទទួលខុសត្រូវចំពោះការបកស្រាយមិនត្រឹមត្រូវណាមួយ ឬការបកស្រាយមិនត្រឹមត្រូវលើភាពជាក់ស្តែង ដោយភាគីទីបីដែលមិនបានទទួលសិទ្ធិអនុញ្ញាតពាក់ព័ន្ធនឹងការប្រកួតនេះដែលបានផ្សព្វផ្សាយលើប្រព័ន្ធផ្សព្វផ្សាយ ឯកសារផ្សព្វផ្សាយ ឬការផ្សាយពាណិជ្ជកម្ម។

៥.៦ ស្ថិតក្នុងកម្រិតមួយដែលច្បាប់បានអនុញ្ញាត ធនាគារកម្ពុមិនរាប់បញ្ចូល និងប្រកាសមិនទទួលខុសត្រូវចំពោះការអះអាង ការធានា ឬការយល់ព្រម ការបង្ហាញ ឬការបញ្ជាក់ ការសរសេរ ឬនិយាយដោយមិនមានកម្រិតកំណត់ចំពោះរាល់ការផ្សព្វផ្សាយលើរាល់ប្រព័ន្ធផ្សព្វផ្សាយ មានដូចជាការធានាគុណភាព គុណភាពទំនិញ ឬឧបករណ៍ហាត់ប្រាណសម្រាប់គោលបំណងជាក់លាក់ណាមួយដែលពាក់ព័ន្ធនឹងការប្រកួតនេះ។

៥.៧ ក្នុងករណីមិនមានសង្គតិភាពរវាងខ និងលក្ខខណ្ឌ និងការផ្សាយពាណិជ្ជកម្ម យុទ្ធនាការ ប្រូម៉ូសិនការផ្សាយជាសាធារណៈ និងព័ត៌មានផ្សេងៗពាក់ព័ន្ធ ឬជាប់ទាក់ទងទៅនឹងការប្រកួតនេះ ខ និងលក្ខខណ្ឌទាំងនេះត្រូវយកជាគោល។

៥.៨ ធនាគារកម្ពុរក្សាសិទ្ធិ៖

ក. បន្ថែម លុបចោល ឬកែប្រែខ និងលក្ខខណ្ឌពីពេលមួយទៅពេលមួយ ទាំងស្រុង ឬផ្នែកណាមួយតាមរយៈការជូនដំណឹងជាមុនទៅអ្នកមានសិទ្ធិចូលរួម តាមរយៈការផ្សព្វផ្សាយលើគេហទំព័ររបស់ធនាគារកម្ពុ បិទផ្សាយការជូនដំណឹងនៅសាខាធនាគារកម្ពុ ឬបណ្តាញផ្សេងទៀតតាមការកំណត់របស់ធនាគារកម្ពុពីពេលមួយទៅពេលមួយ ហើយខ និងលក្ខខណ្ឌដែលបានកែប្រែមានប្រសិទ្ធភាពលើការផ្តល់ ឬការអះអាងដែលមាននៅក្នុងឯកសារផ្សព្វផ្សាយអំពីការប្រកួតនេះ។

ខ. លុបចោល ដក ព្យួរ ឬបញ្ចប់យុទ្ធនាការនេះមុនពេលផុតកំណត់នៃការប្រកួត ទាំងស្រុង ឬផ្នែកណាមួយ តាមរយៈការជូនដំណឹងជាមុនទៅអ្នកមានសិទ្ធិចូលរួម តាមរយៈការផ្សព្វផ្សាយលើគេហទំព័ររបស់ធនាគារកម្ពុ បិទផ្សាយការជូនដំណឹងនៅសាខាធនាគារកម្ពុ ឬបណ្តាញផ្សេងទៀតតាមការកំណត់ដោយរបស់ធនាគារកម្ពុពីពេលមួយទៅពេលមួយ។ ដើម្បីជៀសវាងការភ័ន្តច្រឡំ ការលុបចោល ការដក ការព្យួរ ឬការបញ្ចប់មិនបានផ្តល់សិទ្ធិដល់អ្នកមានសិទ្ធិចូលរួមទាមទារ ឬទទួលសំណងពីធនាគារកម្ពុដែលផ្តើមចេញពីការខាតបង់ ឬខូចខាតដែលអ្នកមានសិទ្ធិចូលរួមបានរ៉ាប់រង ឬទូទាត់ មិនថាបញ្ហានោះបានកើតឡើងដោយផ្ទាល់ ឬដោយប្រយោលដោយសារការលុបចោល ការដក ការព្យួរ ឬការបញ្ចប់នេះ និង

គ. ខ និងលក្ខខណ្ឌទាំងនេះត្រូវបានគ្រប់គ្រង និងបង្កើតស្របតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ហើយអ្នកមានសិទ្ធិចូលរួម យល់ព្រមបញ្ជូនទៅតុលាការមានសមត្ថកិច្ចនៃព្រះរាជាណាចក្រកម្ពុជា។

*****************************************************************************************************

សូមរំលឹកជូនថាទំព័រនេះត្រូវបានទុកទំនេរដោយចេតនារបស់ធនាគារ

*****************************************************************************************************